អន្តរប្រិយ

សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ សំនួរនិងចម្លើយស្តីអំពីសិទ្ធិមនុស្ស (តពីលេខមុន)

www.hoksavann.org

ថ្ងៃទី១២ តុលា ២០១២



៧- សំនួរ ៖ តើសិទ្ធិមនុស្សសំរាប់តែពួកអ្នកមានទ្រព្យទេឬ ?

ចម្លើយ ៖ ពួកអ្នកខ្លះដែលកាន់រដ្ឋអំណាចនៅប្រទេសក្រីក្រនិយាយថា សិទ្ធិ, សេរីភាព និងប្រជាធិបតេយ្យពេញលក្ខណៈ ត្រូវតែរង់ចាំទំរាំប្រទេសសំបូរសប្បាយសិន ទើបអនុវត្តបាន ។ គំនិតបោកប្រាសនេះ ពុំគួរឲ្យអ្នកណាជឿឡើយ ។ ពួកអ្នកដឹកនាំនយោបាយទាំងឡាយណា ដែលនិយាយយ៉ាងហ្នឹង គឺសុទ្ធជាពួកពុករលួយ, លួចប្រាក់ជាតិ ហើយភ័យខ្លាចពលរដ្ឋដែលមានសិទ្ធិសេរីភាព ស្រែកតវ៉ាប្រឆាំងនឹងអំពើពុករលួយនេះ ។ តាមពិត អាជ្ញាធរដែលឃោរឃៅនិងពុករលួយ តែងតែខ្លាចក្រែងនូវរបបប្រជាធិបតេយ្យពិតៗ ព្រោះអីរបបនេះអាចបើកលទ្ធភាពឲ្យប្រជារាស្ត្របោះឆ្នោតទម្លាក់ពួកគេចោល ។

រីឯសិទ្ធិផ្នែកសង្គមនិងសេដ្ឋកិច្ច ដូចជាការផ្តល់ជូនពលរដ្ឋនូវសន្តិសុខសង្គម (គឺការឧបត្ថម្ភជូនប្រជាពលរដ្ឋនូវទីជំរក, អាហារ និងការព្យាបាលរោគ), ការសិក្សាតទៅថ្នាក់ខ្ពស់ដោយឥតគិតថ្លៃ ឬការព្យាបាលជម្ងឺដោយមិនបាច់បង់ប្រាក់ជាដើមនោះ អាស្រ័យនៅលើការរីកចំរើនខាងវិស័យសេដ្ឋកិច្ចរបស់ប្រទេស ។ ហើយច្បាប់សិទ្ធិមនុស្សអន្តរជាតិ បានទទួលស្គាល់បញ្ហានេះ ។ ប៉ុន្តែទោះបីរដ្ឋាភិបាលក្រីក្រយ៉ាងណាក៏ដោយ ក៏មិនត្រូវធ្វើបាបពលរដ្ឋ, មិនត្រូវហាមឃាត់ពលរដ្ឋមិនឲ្យជឿសាសនា, មិនត្រូវបំផ្លាញសាសនានិងវប្បធម៌របស់ពលរដ្ឋឡើយ ។

៨- សំនួរ ៖ តើគេអាចដកហូតសិទ្ធិចេញពីខ្លួនមនុស្សបានឬទេ ?

ចម្លើយ ៖ សិទ្ធិមួយណាក៏មិនត្រូវរំលោភដែរ ។ ហើយគេពុំអាចដកហូតសិទ្ធិចេញពីអ្នកណាបានដែរ ។ ព្រោះអ្វីសិទ្ធិទាំងនេះកើតមាននៅក្នុងខ្លួនមនុស្សតាំងតែពីកំណើត ហើយពុំអាចផ្ទេរផ្លាស់ពីម្នាក់ទៅម្នាក់ទៀតបានឡើយ ។ និយាយឲ្យខ្លី គឺរូបអ្នកណា សិទ្ធិអ្នកហ្នឹង ។

៩- សំនួរ ៖ តើអ្នកណារំលោភលើសិទ្ធិមនុស្ស ?

ចម្លើយ ៖ អ្នកដែលតែងរំលោភសិទ្ធិមនុស្ស គឺរដ្ឋាភិបាល ឬភ្នាក់ងាររដ្ឋាភិបាល ដែលទទួលបញ្ជាពីអាជ្ញាធរនយោបាយ ។ អ្នកឯទៀតៗដែលអាចប្រព្រឹត្តមិនគប្បីក្នុងរឿងសិទ្ធិមនុស្សនេះដែរ គឺអ្នកកាន់រដ្ឋអំណាចនានា, ទាហាន, តម្រួត ឬជំពូកមនុស្សផ្សេងទៀតដែលមានអំណាចក្នុងកិច្ចការរបស់រដ្ឋ ។ ជួនកាលភ្នាក់ងាររដ្ឋការប្រព្រឹត្តកំហុសនេះដោយចេតនាផ្ទាល់ខ្លួន ជួនកាលទៀតអាជ្ញាធរថ្នាក់លើដាក់បញ្ជាឲ្យគេប្រព្រឹត្តបទរំលោភអស់ទាំងនេះ ។

កាលណាពលរដ្ឋណាវាយតប់ លួចប្លន់ ឬធ្វើទុក្ខបុកម្នេញពលរដ្ឋណាម្នាក់ទៀត គេចាត់ទុកថាជាបទឧក្រិដ្ឋធម្មតា ។ ប៉ុន្តែបើមានការប្រព្រឹត្តបែបនេះមកពីមជ្ឈដ្ឋានដែលមានរដ្ឋអំណាចទៅលើរាស្ត្រ ឬពលរដ្ឋណាមួយ គេចាត់ថាជាការរំលោភសិទ្ធិមនុស្ស ។

១០- សំនួរ ៖ តើអ្វីដែលបណ្តាលឲ្យមានការរំលោភសិទ្ធិមនុស្ស ?

ចម្លើយ ៖ ការរំលោភសិទ្ធិមនុស្ស កើតមកពីមូលហេតុច្រើនយ៉ាង ។ ជួនកាលការរំលោភសិទ្ធិកើតពីរឿងតូចតាច ដូចជាការអនុវត្តន៍ច្បាប់ពុំត្រឹមត្រូវ ។ ឧទាហរណ៍ ភ្នាក់ងារប៉ូលិស ឬភ្នាក់ងារក្រសួងតុលាការ ពុំបានយកចិត្តទុកដាក់ពីរឿងច្បាប់ឲ្យបានត្រឹមត្រូវ ក៏ប្រើអំណាចខ្លះៗ ដើម្បីបង្ខំឲ្យជនជាប់ចោទទទួលសារភាព ឬដាក់ទោសដោយពុំសមស្របតាមលក្ខណៈច្បាប់ ។ ការរំលោភសិទ្ធិបែបនេះតែងតែកើតមាននៅស្ទើរតែគ្រប់ប្រទេស សូម្បីនៅប្រទេសដែលមានប្រព័ន្ធច្បាប់ និងប្រព័ន្ធនយោបាយល្អបំផុតក៏ដោយ ។

អំពើរំលោភខ្លះទៀតកើតមកពីភ្នាក់ងាររដ្ឋការដែលពុករលួយ ព្រោះថាបើមិនបំបិទសេរីភាពពលរដ្ឋទេ ពលរដ្ឋមុខជានឹងតវ៉ាប្រឆាំងនឹងអំពើពុករលួយ ។

អំពើរំលោភខ្លះទៀតកើតឡើងដោយសារអ្នកដឹកនាំនយោបាយ ឬបក្សនយោបាយយល់ថា មានតែពួកគេទេដែលល្អប្រសើរ ហើយបើជនណាដែលពុំមានមតិស្របនឹងពួកគេ ពួកគេត្រូវតែបំបាក់សេរីភាពជននោះ ។

អំពើរំលោភសិទ្ធិមនុស្សកើតឡើងដោយសារតែអ្នកកាន់រដ្ឋអំណាចខ្លាចពលរដ្ឋធ្វើការទិះទៀន ឬទាមទារឲ្យប្តូរអ្នកដឹកនាំដែលមិនត្រឹមត្រូវចេញ ប្រសិនបើពលរដ្ឋមានសិទ្ធិពេញលេញនោះ (ជាពិសេសសិទ្ធិក្នុងការនិយាយស្តី) ។

ការរំលោភសិទ្ធិខ្លះទៀតដែលមានប្រព័ន្ធច្បាស់លាស់ តែងតែកើតមកអំពីការពុំស្របមតិគ្នាខាងវិស័យសង្គម,វិស័យសេដ្ឋកិច្ច និងវិស័យនយោបាយ ពីសំណាក់ពួកក្រុមដែលមានពូជសាសន៍ខុសគ្នា ឬវណ្ណៈសង្គមខុសគ្នា ។

ត្រង់ប្រការនេះ អ្នកដឹកនាំខ្លះយល់ឃើញថា មធ្យោបាយដែលយកទៅដោះស្រាយបញ្ហាសង្គមនេះ គឺការប្រើអំណាចកៀបសង្កត់ ឬរហូតទៅដល់ការសម្លាប់រង្គាលឲ្យអស់នូវគូបដិបក្ខ ឬសត្រូវរបស់គេ ទោះជាសត្រូវមែនៗ ឬគ្រាន់តែតាមការស្មានរបស់គេក្តី ។

(នៅមានត)